**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥

លេខ : ៩០/១៥ តកក.ណ.ណ.ន

# សេចក្តីណែនាំ
# ស្តីពី
# បែបបទ និងនីតិវិធីសម្បថ ជនបរទេស
# ដែលព្រះមហាក្សត្រទ្រង់បានប្រទានសញ្ជាតិខ្មែររួចហើយ

តាមអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ស្តីពីបែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិ និងតាមអនុក្រឹត្យលេខ ២៨៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ស្តីពីបែបបទ និងនីតិវិធីនៃការសុំសញ្ជាតូបនីកម្ម បានផ្តល់សមត្ថកិច្ចជូនតុលាការកំពូលរៀបចំធ្វើពិធីសម្បថចូលសញ្ជាតិ ។ ដូច្នេះ **ប្រធានតុលាការកំពូល** សូមធ្វើការណែនាំដល់ ឯកឧត្តមអនុប្រធាន លោក លោកស្រី ជាចៅក្រម ក្រឡាបញ្ជី និងមន្ត្រីពាក់ព័ន្ធនៃតុលាការកំពូលទាំងអស់ឲ្យអនុវត្តតាមវិធានដូចខាងក្រោមក្នុងការធ្វើពិធីសម្បថនេះ ៖

## ក. ផ្នែករដ្ឋបាល ៖

១.ត្រូវធ្វើសៀវភៅចុះបញ្ជីស្តីពីការធ្វើសម្បថនៅសភារដ្ឋប្បវេណីរហូតដល់ពេលអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលត្រូវបានបង្កើត ។

២.ប្រធានតុលាការកំពូល ៖
- ចាត់តាំងក្រុមប្រឹក្សានៃសភារដ្ឋប្បវេណី ជាក្រុមប្រឹក្សានៃពិធីសម្បថ ។
- កំណត់កាលបរិច្ឆេទសម្បថ ។
- ជូនដំណឹងស្តីពីកិច្ចការធ្វើសម្បថទៅមហាអយ្យការអមតុលាការកំពូល ។

៣.ប្រធានក្រុមប្រឹក្សា ៖
- ជូនដំណឹងស្តីពីកាលបរិច្ឆេទការធ្វើសម្បថទៅសាមីខ្លួន និងក្រសួងមហាផ្ទៃ ។
- ធ្វើកំណត់ហេតុស្តីពីការធ្វើសម្បថ ។
- បញ្ជូនកំណត់ហេតុទៅក្រសួងមហាផ្ទៃ ។

## ខ. ផ្នែកនីតិវិធីសម្បថ ៖

ប្រធានក្រុមប្រឹក្សា ៖
១.ប្រកាសបើកពិធីសម្បថ និងប្រាប់ពីសមាសភាពក្រុមប្រឹក្សាសម្បថ ។
២.ក្រឡាបញ្ជីរាយការណ៍ពីវត្តមាន-អវត្តមានអ្នកចូលរួម ។

មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-២១២ ៨២៦ ទូរសារ : ៨៥៥-២៣-២១២ ៨២៦
Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia Tel : 855-23-212 826 Fax : 855-23-212-826

៣.អញ្ជើញសាមីខ្លួនមកឈរមុខតុលាការ និងសួរប្រវត្តិរូបសង្ខេប ។

៤.អញ្ជើញតំណាងក្រសួងយុត្តិធម៌ ឬក្រសួងមហាផ្ទៃដើម្បីអានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ។

៥.អញ្ជើញតំណាងមហាអយ្យការផ្តល់យោបល់ទាក់ទងនឹងនីតិវិធីសម្បថ ។

៦.ឲ្យអ្នកស្បថលើកដៃសំពះគ្រប់ៗគ្នារួចថាតាមការអានរបស់ក្រឡាបញ្ជី ធ្វើពិធីសច្ចាប្រណិធានថា ៖

" ខ្ញុំសូមសច្ចាជាឱឡារិកថា ខ្ញុំមានភក្តីភាព និង សេចក្តីស្មោះចំពោះជាតិមាតុភូមិកម្ពុជារបស់ខ្ញុំហើយប្តេជ្ញាធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារ និង គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទាំងក្នុងពេលបច្ចុប្បន្នទាំងក្នុងពេលអនាគត " ។

" ខ្ញុំសូមប្តេជ្ញាជាឱឡារិកថា នឹងតាំងខ្លួនជាពលរដ្ឋខ្មែរដ៏ល្អ ហើយហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីចូលរួមចំណែកក្នុងការពារខឿនឯករាជ្យជាតិ អធិបតេយ្យភាព បូរណភាពទឹកដី សន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ព្រមទាំងលើកកំពស់កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត " ។

៧.ប្រធានក្រុមប្រឹក្សា ប្រកាសទទួលស្គាល់ សមាជិក សមាជិកា ដែលបានចូលមកធ្វើសម្បថនាពេលនេះ មានចំនួន.....រូប(រៀបរាប់ឈ្មោះ) គឺជាពលរដ្ឋខ្មែរពេញលក្ខណៈច្បាប់ចាប់ពីថ្ងៃនេះតទៅ ។

៨.ប្រធានក្រុមប្រឹក្សាអញ្ជើញតំណាងឡើងធ្វើការប្តេជ្ញាចិត្តដោយឲ្យអ្នកស្បថថាតាម ៖

៩.មតិផ្តាំផ្ញើ និងការណែនាំរបស់ប្រធានក្រុមប្រឹក្សានៃពិធីសម្បថ ។

ប្រធានក្រុមប្រឹក្សាប្រកាសបិទកម្មវិធី ។

ខ្ញុំសង្ឃឹម និងជឿជាក់ថា **ឯកឧត្តមអនុប្រធាន លោក លោកស្រី** នឹងអនុវត្តតាមខ្លឹមសារ នៃសេចក្តីណែនាំខាងលើនេះឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

**ប្រធានតុលាការកំពូល**

**ឌិត មុន្ទី**

**ចម្លងជូន ៖**

- មហាអយ្យការអមតុលាការកំពូល
- ក្រសួងយុត្តិធម៌
- ឯកសារ " កាលប្បវត្តិ "